## ទិដ្ឋភាពទូទៅនៃកម្មវិធី៖
## «កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន ឆ្នាំ២០២៥-២០២៦»
## «កម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍»

### ១. តើកម្មវិធីនេះមានប្រតិបត្តិការដូចម្តេច ?

កម្មវិធីអាហារូបករណ៍សិល្បៈអមតៈ អាន ចនផន ជាកម្មវិធីស្នូលនៅក្នុងកម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍នៃអង្គការសិល្បៈខ្មែរអមតៈ។ កម្មវិធីនេះមានការប្រកួតប្រជែងខ្ពស់ ដោយសារជ័យលាភីមានតែ ១០ កន្លែង ក្នុងមួយឆ្នាំ ហើយយ៉ាងហោចណាស់ ៥ កន្លែង ត្រូវផ្តល់ជូននារី។ ដូច្នេះអ្នកដែលចាប់អារម្មណ៍ តម្រូវឱ្យដាក់ពាក្យស្នើសុំបញ្ជាក់ពីជំនាញដែលចង់រៀននិងកន្លែងរៀន ឆ្លងកាត់ការសម្រិតសម្រាំង ជម្រុះសកម្មភាពធ្វើការជាក្រុម និងការសម្ភាស។ អ្នកជ្រើសរើសនិងវាយតម្លៃជាគណៈកម្មការឯករាជ្យដែលមានជំនាញសិល្បៈវប្បធម៌។ អ្នកជាប់ជ័យលាភីនឹងទទួលបានប្រាក់ឧបត្ថម្ភយកទៅរៀនជំនាញដែលស្នើសុំ និងចូលរួមវគ្គបណ្តុះគុណតម្លៃដែលរៀបចំដោយសិល្បៈខ្មែរអមតៈដើម្បីអភិវឌ្ឍគុណតម្លៃបន្ថែម។

### ២. តើគោលដៅរបស់កម្មវិធីមានអ្វីខ្លះ ?

កម្មវិធីនេះមានគោលដៅ ជួយគាំទ្រដល់អ្នកនៅក្នុងវិស័យសិល្បៈវប្បធម៌ដែលត្រូវការឱកាសនេះ អាចសិក្សានិងបញ្ចប់ការសិក្សាជំនាញសិល្បៈវប្បធម៌បានដោយជោគជ័យ អភិវឌ្ឍគុណតម្លៃផ្ទាល់ខ្លួន ដែលមានការគិតទូលំទូលាយ និងបណ្តុះសក្តានុពលលើការដឹកនាំក្នុងវិស័យសិល្បៈវប្បធម៌។

### ៣. តើអត្ថប្រយោជន៍នៃកម្មវិធីនេះមានអ្វីខ្លះ ?

- ទទួលបានប្រាក់ឧបត្ថម្ភការសិក្សាលើជំនាញស្នើសុំចំនួន ១,៥០០ ដុល្លារ ក្នុង១ឆ្នាំ
- ទទួលបានការបណ្តុះបណ្តាលអភិវឌ្ឍគុណតម្លៃ បង្កើនចំណេះដឹងក្នុងវិស័យសិល្បៈវប្បធម៌និងស្វែងយល់បញ្ហាក្នុងសង្គមដែលសិល្បៈអាចចូលរួមចំណែកនៃដំណោះស្រាយ
- ឱកាសអនុវត្តគម្រោងខ្នាតតូចជាក្រុមដែលជះឥទ្ធិពលវិជ្ជមានដល់សហគមន៍និងសង្គម
- ការធានារ៉ាប់រងលើការចំណាយពេលមានគ្រោះថ្នាក់ជាយថាហេតុ
- បានឱកាសទៅស្គាល់ទីតាំងសិល្បៈវប្បធម៌នានានៅក្នុងទីក្រុងភ្នំពេញ
- បង្កើនបណ្តាញនៅក្នុងសហគមន៍សិល្បៈវប្បធម៌

### ៤. តើនរណាអាចដាក់ពាក្យក្នុងកម្មវិធីនេះ?

ដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់កម្មវិធីនេះ អ្នកត្រូវ ៖

- មានអាយុយ៉ាងតិច១៨ឆ្នាំ
- ជាពលរដ្ឋកម្ពុជា និងកំពុងរស់នៅក្នុងប្រទេសកម្ពុជា
- រៀនជំនាញសិល្បៈវប្បធម៌ណាមួយយ៉ាងតិច ៣ ឆ្នាំ ឬ ធ្វើការក្នុងវិស័យសិល្បៈវប្បធម៌យ៉ាងតិច ៣ ឆ្នាំ

- មានគោលបំណងនិងឆន្ទៈអភិវឌ្ឍជំនាញសិល្បៈនិងអាជីពរបស់ខ្លួននៅក្នុងវិស័យសិល្បៈវប្បធម៌ ឱ្យឈានទៅរកកម្រិតអាជីព
- មានវត្តមានក្នុងថ្នាក់រៀនដែលបានស្នើសុំអាហារូបករណ៍យ៉ាងហោចណាស់ ៩០% ក្នុង ១ត្រីមាស (៣ខែ)
- មានពេលវេលាគ្រប់គ្រាន់ចូលរួមគ្រប់វគ្គបណ្តុះគុណតម្លៃដែលសិល្បៈខ្មែរអមតៈរៀបចំ ដែលភាគច្រើនកើតឡើងនៅថ្ងៃចុងសប្តាហ៍ ពេញ១ថ្ងៃ
- ប្រើប្រាស់ប្រយោជន៍ពីការឧបត្ថម្ភអាហារូបករណ៍ ឱ្យស្របទៅនឹងគោលបំណងនៃកម្មវិធី

## ៥. តើលក្ខខណ្ឌជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

លក្ខខណ្ឌដែលនឹងប្រើប្រាស់ដើម្បីជ្រើសរើសអ្នកចូលរួមកម្មវិធីនេះ មានដូចជា៖

- ត្រូវនឹងលក្ខខណ្ឌ (មានអាយុយ៉ាងតិច១៨ឆ្នាំ, ជាពលរដ្ឋកម្ពុជា ឬកាន់ទិដ្ឋាការ K-Visa និងកំពុងរស់នៅក្នុងប្រទេសកម្ពុជា, រៀនជំនាញសិល្បៈវប្បធម៌ណាមួយយ៉ាងតិច ៣ ឆ្នាំ ឬ ធ្វើការក្នុងវិស័យសិល្បៈវប្បធម៌យ៉ាងតិច ៣ ឆ្នាំ
- ការពន្យល់ពីទំនាក់ទំនងរវាងជំនាញដែលបេក្ខជនស្នើសុំរៀន ទៅនឹងជំនាញរៀនឬបទពិសោធន៍ដែលមាន, ឬការផ្សាភ្ជាប់ជំនាញសិល្បៈវប្បធម៌របស់បេក្ខជនដើម្បីបម្រើសង្គម/សិល្បៈវប្បធម៌, ការបង្ហាញឱ្យឃើញពីឆន្ទៈឬការប្តេជ្ញាចិត្តសម្រេចគោលដៅ, មានផែនការច្បាស់លាស់ក្នុងការប្រើប្រាស់ថវិកាអាហារូបករណ៍ ដើម្បីផ្គត់ផ្គង់ការសិក្សានិងការអភិវឌ្ឍខ្លួន
- បេក្ខជនមានគំនិតច្នៃប្រតិដ្ឋប្រកបដោយហេតុផលនិងគោលបំណង ព្រមទាំងមានភាពជាអ្នកដឹកនាំនិងការប្រាស្រ័យទាក់ទងល្អនៅពេលធ្វើការជាក្រុម
- បេក្ខជនស្គាល់ខ្លួនឯងច្បាស់ ពីតម្រូវការនិងគោលដៅ និងយល់ច្បាស់ពីគោលបំណងកម្មវិធីអាហារូបករណ៍នេះ

សមភាពនិងបរិយាបន្ន គឺជាគុណតម្លៃស្នូលរបស់អង្គការសិល្បៈខ្មែរអមតៈ។ យោងតាមគុណតម្លៃនេះ៖

- យ៉ាងហោចណាស់ជ័យលាភីចំនួន ៥០% នឹងផ្តល់សម្រាប់បេក្ខនារី។
- យ៉ាងហោចណាស់ក៏ ៣០% ដែរ ដែលប្រាក់ឧបត្ថម្ភសម្រាប់ផ្តល់ជូនបេក្ខជនដែលមិនធ្លាប់ទទួលបានអាហារូបករណ៍ពីអង្គការសិល្បៈខ្មែរអមតៈ ពីមុនមក។

បេក្ខជនដែលមកពីសហគមន៍ដែលខ្វះការយកចិត្តទុកដាក់និងឱ្យតម្លៃ ទទួលបានការលើកទឹកចិត្តខ្ពស់ក្នុងការដាក់ពាក្យ។

## ៦. តើដំណើរការនៃការជ្រើសរើសសម្រាប់កម្មវិធីនេះ មានអ្វីខ្លះ ?

- នៅពេលអ្នកផ្ញើពាក្យស្នើសុំមក យើងនឹងបញ្ជាក់ប្រាប់វិញប្រសិនបើយើងបានទទួល។ ប្រសិនបើអ្នកមិនបានទទួលដំណឹងក្នុងអំឡុងពេល ៣ ថ្ងៃនៃថ្ងៃធ្វើការទេនោះ សូមទាក់ទងមកយើងម្តងទៀត។

- បន្ទាប់ពីកាលបរិច្ឆេទឈប់ទទួលពាក្យ យើងនឹងពិនិត្យមើលពាក្យស្នើសុំភ្លាមៗ។
- ពាក្យស្នើសុំទាំងអស់ដែលត្រឹមត្រូវតាមលក្ខខណ្ឌ នឹងត្រូវបានពិនិត្យម្តងទៀតដោយគណៈកម្មការជ្រើសរើសឯករាជ្យ យោងទៅតាមលក្ខខណ្ឌនៃការជ្រើសរើសនិងប្រព័ន្ធផ្តល់ពិន្ទុ។
- បេក្ខជនដែលបានជាប់ដំណាក់កាលពិនិត្យពាក្យស្នើសុំ នឹងត្រូវអញ្ជើញចូលរួម "សកម្មភាពធ្វើការជាក្រុម" ជាមួយបេក្ខជនផ្សេងទៀត នៅអង្គការសិល្បៈខ្មែរអមតៈ (សិល្បៈខ្មែរអមតៈនឹងរ៉ាប់រងថ្លៃចំណាយមួយចំនួនសម្រាប់បេក្ខជនមកពីតាមខេត្ត)។
- បេក្ខជនដែលបានជាប់ដំណាក់កាល "សកម្មភាពធ្វើការជាក្រុម" នឹងត្រូវអញ្ជើញចូល "សម្ភាសន៍ជាមួយគណៈកម្មការ" នៅថ្ងៃបន្ទាប់ នៅអង្គការសិល្បៈខ្មែរអមតៈ
- សម្រាប់បេក្ខជនជ័យលាភីក្រោយសម្ភាសន៍ យើងនឹងជម្រាបដំណឹងជូននៅត្រឹមសប្តាហ៍ទីបួន ខែកក្កដា ឆ្នាំ២០២៤
- សម្រាប់បេក្ខជនទាំងអស់ យើងនឹងជម្រាបដំណឹងអំពីលទ្ធផលនៅត្រឹមសប្តាហ៍ទីបួន ខែកក្កដា ឆ្នាំ២០២៤

## ៧. តើកម្មវិធីនេះមានរចនាសម្ព័ន្ធនិងពេលវេលាអនុវត្តដូចម្តេច?

- បន្ទាប់ពីជាប់ជ័យលាភី អ្នកទទួលបានអាហារូបករណ៍នឹងចូលរៀនជំនាញដែលបានស្នើសុំអាហារូបករណ៍ ដែលកាលវិភាគរៀនអាស្រ័យលើស្ថាប័នបង្រៀនឬការព្រមព្រៀងជាមួយគ្រូឯកជន
- អ្នកទទួលបានអាហារូបករណ៍នឹងចូលរួមជំនួបសំណេះសំណាលជាមួយអ្នកគ្រប់គ្រងកម្មវិធី ស្តីពីវឌ្ឍនភាពការសិក្សានិងការប្រឹក្សាយោបល់ផ្សេងៗ ដែលកើតឡើងរៀងរាល់៦សប្តាហ៍ ម្តង
- ស្របពេលនេះដែរ អ្នកទទួលបានអាហារូបករណ៍ក៏តម្រូវឱ្យចូលរួមវគ្គបណ្តុះគុណតម្លៃ ទៅតាមកាលវិភាគដែលផ្តល់ជូនដោយសិល្បៈខ្មែរអមតៈ ដែលភាគច្រើនកើតឡើងនៅថ្ងៃចុងសប្តាហ៍ពេញ១ថ្ងៃ

## ៨. តើនរណាជាគ្រូបណ្តុះបណ្តាលវគ្គបណ្តុះគុណតម្លៃក្នុងឆ្នាំទី១?

គ្រូបណ្តុះបណ្តាលសម្រាប់វគ្គបណ្តុះគុណតម្លៃក្នុងឆ្នាំទី១គឺលោកស្រី **ឃុត សុចំប៉ាវឌ្ឍន៍** ។ លោកស្រី ជាស្ថាបនិកស្ថាប័នទស្សនៈ ដែលផ្តល់វគ្គបណ្តុះបណ្តាល នាំមកនូវដំណោះស្រាយសម្រាប់ជីវិត និងជាទីប្រឹក្សាឯករាជ្យផ្នែកបណ្តុះបណ្តាល។

កម្មវិធីនេះ ត្រូវបានសម្របសម្រួលដោយក្រុមការងារអង្គការសិល្បៈខ្មែរអមតៈ រួមមាន លោក ឥន្ទ សម៉ាណាក់ ជាអ្នកគ្រប់គ្រងកម្មវិធីបណ្តុះបណ្តាលនិងអភិវឌ្ឍន៍ និង កញ្ញា យ៉ុន សុខខន ជានាយិកាកម្មវិធី។

## ៩. កាលបរិច្ឆេទសំខាន់ៗ

| កាលបរិច្ឆេទ | សកម្មភាព |
|---|---|
| ១ មីនា - ៣១ ឧសភា ២០២៥ | រយៈពេលបើកទទួលពាក្យអាហារូបករណ៍ |
| សប្តាហ៍ទីបី មិថុនា ២០២៥ | ផ្តល់ដំណឹងដល់អ្នកជាប់ទៅវគ្គជម្រុះ |
| ៥ កក្កដា ២០២៥ | វគ្គជម្រុះ សកម្មភាពធ្វើការជាក្រុម |
| ៦ កក្កដា ២០២៥ | វគ្គសម្ភាសចុងក្រោយជាមួយគណៈកម្មការ |
| សប្តាហ៍ទីបួន កក្កដា ២០២៥ | ផ្តល់ដំណឹងលទ្ធផលទៅបេក្ខជនដែលត្រូវបានជ្រើសរើស |
| សប្តាហ៍ទីបួន កក្កដា ២០២៥ | ផ្តល់ដំណឹងលទ្ធផលទៅបេក្ខជនទាំងអស់ |
| ខែសីហា ២០២៥ | បេក្ខជនជ័យលាភីផ្តល់ការបញ្ជាក់ពីអ្នកធានាអះអាង |
| ខែកញ្ញា ២០២៥ | ការណែនាំពីកម្មវិធីអាហារូបករណ៍ |
| ដើមខែតុលា ២០២៥ | បើកប្រាក់អាហារូបករណ៍សម្រាប់ត្រីមាសលើកទី១ |